ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

## រវាង

## ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា

## និង

## អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ( IJM )

## ស្តីពី

## ការចូលរួមសកម្មភាពមនុស្សធម៌

## ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា

## បុព្វកថា

<u>ដោយហេតុថា</u> ៖ **ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា** បានសម្តែងនូវបំណងប្រាថ្នា ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់នេះ ថាអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិបានរួមចំណែកធ្វើការងារមនុស្សធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមក។

<u>ដោយហេតុថា</u> ៖ **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** បានរួមចំណែកជាមួយក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាក្នុងការសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

<u>ដោយហេតុថា</u> ៖ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមមាន អំពើកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងវិស័យការងារ នេសាទ ស្រ្តីធ្វើការតាមផ្ទះ ការសុំទាន សំណង់ រោងចក្រ កសិកម្ម ឧស្សាហកម្ម និងអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រសួងមហាផ្ទៃតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ហាញបំណងប្រាថ្នាបន្តកិច្ចសហប្រតិបត្តិការរួមគ្នា។

<u>ដោយហេតុថា</u> ៖ **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានានៃព្រះរាជាណាចក្រកម្ពុជា និងធ្វើកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយ **ក្រសួងមហាផ្ទៃ** ដើម្បីសម្រេចបាននូវគោលដៅមនុស្សធម៌រួមរបស់ខ្លួន។

ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) តទៅនេះហៅថា **"គូភាគី"**។ គូភាគីបានព្រមព្រៀងគ្នាដូចខាងក្រោម៖

## ប្រការ១
## គោលបំណង

អនុស្សរណៈនេះមានគោលបំណងកំណត់ អំពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)ដើម្បីចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

## ប្រការ២
## សកម្មភាពនៃកិច្ចសហប្រតិបត្តិការ

### ១-ការប្រមូលនិងការផ្តល់ព័ត៌មានសម្ងាត់

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការជាមួយក្រសួងមហាផ្ទៃដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការដើម្បីប្រមូល និងផ្តល់ព័ត៌មាននៃសកម្មភាពដែលពាក់ព័ន្ធអំពើជួញដូរមនុស្សតាមបណ្តាគ្រឹះស្ថាន និងទីកន្លែងផ្សេងទៀតដែលសង្ស័យថា មានបុរស ស្ត្រី និងកុមារ ត្រូវបានជួញដូរ។

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវមានរបាយការណ៍ និងព័ត៌មានលម្អិតដែលប្រមូលបានជូនអគ្គស្នងការដ្ឋាននគរបាលជាតិតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននូវសកម្មភាពល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវបង្ហាញទីតាំងកំណត់អត្តសញ្ញាណបឋម និងរបាយការណ៍ស្តីពីជនរងគ្រោះដោយអំពើជួញដូរមនុស្សឬការកេងប្រវ័ញ្ចកម្លាំង ពលកម្មមកអគ្គស្នងការដ្ឋាននគរបាលជាតិតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

## ២-ការធ្វើអន្តរាគមន៍ និងការសង្គ្រោះ

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីមានសមត្ថកិច្ចចំណុះក្រសួងមហាផ្ទៃដើម្បីសង្គ្រោះ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សចេញពីទីកន្លែង ឬស្ថានភាព នៃអំពើជួញដូរមនុស្សឬអំពើកេងប្រវ័ញ្ច និងធ្វើឱ្យប្រាកដថាមានការចាប់ខ្លួនជនប្រព្រឹត្តបទល្មើសបញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ ជូនជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីនាំជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

## ៣-ការសម្របសម្រួលក្រោយពេលសង្គ្រោះ

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការដឹកជញ្ជូនជនរងគ្រោះចេញពីកន្លែងកើតហេតុមកកាន់ទីតាំងដែលមានសន្តិសុខ និងមានសុវត្ថិភាព ដើម្បីធ្វើការសម្ភាស ប្រមូលព័ត៌មានដោយមន្ត្រីមានសមត្ថកិច្ច និងបន្ទាប់មកធ្វើការសហការជាមួយមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តក្រោមគោលការណ៍ណែនាំ នៃអនុស្សរណៈនៃការយោគយល់រវាង **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដើម្បីធ្វើការដឹកជញ្ជូន ជនរងគ្រោះ ពីនគរបាលជំនាញទៅកាន់មណ្ឌលថែទាំដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ឬធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញ។

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសម្របសម្រួលជាមួយមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ដូចជា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីផ្តល់ការថែទាំ ជនរងគ្រោះដែលមានវិបត្តិ ជាពិសេសអនីតិជនបន្ទាប់ពីមានការជួយសង្គ្រោះភ្លាមៗ។

## ៤-ការបណ្តុះបណ្តាលមន្ត្រីនគរបាល

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងបណ្ឌិត្យសភានគរបាលកម្ពុជានៃក្រសួងមហាផ្ទៃ ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់បណ្ឌិត្យសភានគរបាលកម្ពុជា ស្តីពីប្រធានបទផ្សេងៗតាមការព្រមព្រៀង នៃក្រុមការងារបច្ចេកទេស ដែលអាចនឹងរួមបញ្ចូលប្រធានបទដូចជាទិដ្ឋភាពទូទៅនៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ការប្រមូលព័ត៌មានព្រហ្មទណ្ឌសម្ងាត់ ការកំណត់អត្តសញ្ញាណជនរងគ្រោះការប្រព្រឹត្តសមរម្យចំពោះកុមារ និងការយល់ដឹងអំពីយេនឌ័រ ការស៊ើបអង្កេតព្រហ្មទណ្ឌ និងការសរសេររបាយការណ៍ ការប្រមូលនិងថែរក្សាភស្តុតាង ការកំណត់អត្តសញ្ញាណ និងការតាមចាប់ខ្លួនជនសង្ស័យបច្ចេកទេសសម្ភាសន៍សាក្សី និងជនរងគ្រោះ បច្ចេកទេសសម្ភាសន៍ជនសង្ស័យ ការការពារសាក្សី និងការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន។

## **ប្រការ៣**
## **ការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ**

**ក្រសួងមហាផ្ទៃ**ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ ព្រមទាំងអង្គភាពជំនាញចំណុះក្រសួងមហាផ្ទៃ បានព្រមព្រៀង ដូចខាងក្រោម៖

១-ទទួលព័ត៌មានសម្ងាត់ និងភស្តុតាងដែលប្រមូលបានទាក់ទងនឹងបទល្មើសនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មដោយបង្ខំ លើបុរស ស្ត្រី និងកុមារ ដែលប្រមូលបានដោយ**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**។

២-សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងចាត់វិធានការឱ្យទាន់ពេលវេលា ក្នុងគោលបំណងចាប់ជនល្មើស និងជួយសង្គ្រោះជនរងគ្រោះ ដែលត្រូវបានកំណត់អត្តសញ្ញាណ។

៣-នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គភាពជំនាញចំណុះ ក្រសួងមហាផ្ទៃ អាចសហការជាមួយ**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ដើម្បីផ្តល់ និងផ្លាស់ប្តូរព័ត៌មាន និងឯកសារ ជាមួយគ្នាទៅវិញទៅមក ដើម្បីឈានទៅបង្ក្រាបទប់ស្កាត់បទល្មើស និងឃាត់ខ្លួនជនសង្ស័យឱ្យបានទាន់ពេលវេលា។

## **ប្រការ៤**
## **ការទទួលខុសត្រូវរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**

១-**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវសហការជាមួយសមត្ថកិច្ចនគរបាលជាតិកម្ពុជាក្នុងការចូលរួមផ្តល់ព័ត៌មានជាជំនួយលើការស៊ើបអង្កេត និងប្រមូលភស្តុតាងនានាពាក់ព័ន្ធអំពើជួញដូរមនុស្សរួមទាំងអំពើកេងប្រវ័ញ្ច និងទីតាំងផ្សេងៗ ដែលបុរស ស្ត្រី និងកុមារត្រូវបានបង្ខំឱ្យ ធ្វើពលកម្មតាមទម្រង់ផ្សេងៗ។

២-**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យភ្នាក់ងារ របស់ខ្លួនមានការចូលរួមក្នុងសកម្មភាពណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់ សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬក៏សកម្មភាពដទៃទៀតដែលអាចបង្ក អន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីជាតិរបស់ពលរដ្ឋកម្ពុជា។

៣-**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវប្រតិបត្តិរាល់សកម្មភាព និងអនុវត្តកម្មវិធីគម្រោងមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជាក្នុងក្របខ័ណ្ឌនៃធនធានបុគ្គលិក និងមូលនិធិរបស់ខ្លួន។ ព្រមទាំងធានាឱ្យបានថា រាល់ការទទួលបានភស្តុតាងនៃការបំពានច្បាប់កម្ពុជាដែលខ្លួនបានប្រមូលនឹងត្រូវបញ្ជូនទៅ នគរបាលមានសមត្ថកិច្ច សម្រាប់ចាត់ វិធានការបន្ត។ រាល់ការចុះប្រមូលព័ត៌មាន **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវតែផ្តល់របាយការណ៍ជូនទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ រាល់នីតិវិធីនៃការប្រមូលព័ត៌មាន ត្រូវមានរបាយការណ៍ ដោយមានការឯកភាពគ្នារវាងភាគីទាំងពីរជាមុន។

៤-**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ត្រូវចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ ដែលទទួលបានការអនុញ្ញាត ពី**ក្រសួងមហាផ្ទៃ** ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ និងជៀសវាងដាច់ខាតពីការពាក់ព័ន្ធនឹងសកម្មភាពបង្កើតប្រាក់ចំណូល និងសកម្មភាពនយោបាយ ដែលមិនបម្រើដល់គោលដៅមនុស្សធម៌របស់**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** ដែលបានប្រកាស។

## ប្រការ៥
## ការដោះស្រាយវិវាទ

វាល់វិវាទដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តអនុស្សរណៈនេះត្រូវដោះស្រាយជាបន្ទាន់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ ឬតាមមធ្យោបាយផ្សេងទៀតដែលគូភាគីព្រមព្រៀង។

## ប្រការ៦
## ការចូលជាធរមាន និងសុពលភាព

អនុស្សរណៈនេះ ចូលជាធរមានចាប់ពីពេលចុះហត្ថលេខាដោយគូភាគី។

អនុស្សរណៈនេះ មានសុពលភាពរយៈពេល ០៣(បី)ឆ្នាំ ហើយនឹងអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីគូភាគី។

## ប្រការ៧
## ការបញ្ចប់

អនុស្សរណៈនេះ អាចបញ្ចប់បានដោយភាគីណាមួយក៏បានដោយការជូនដំណឹងអំពីបំណង បញ្ចប់ការអនុវត្តអនុស្សរណៈនេះ ជូនភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ អនុស្សរណៈនេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈនេះ ត្រូវធ្វើឡើងចំនួន ០២(ពីរ)ច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងនេះមានតម្លៃស្មើគ្នា ដែលពុំមែនជាកិច្ចព្រមព្រៀងបង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។ ក្នុងករណីមានការបកស្រាយខុសគ្នា វិវាទ ឬចំណុចមិនស្របគ្នា គូភាគីត្រូវយកអត្ថបទដែលជាភាសាខ្មែរជាគោល។

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី ២១ . ខែមករា. ឆ្នាំ២០២៦

**ក្រសួងមហាផ្ទៃ**
រដ្ឋលេខាធិការ

ជូ ប៊ុនអេង

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**
នាយកប្រចាំប្រទេស

QUAERITE IUDICIUM · SUBVENITE OPPRESSO

IJM

ជុំ សាឯម

## ប្រការ៥
## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តអនុស្សរណៈនេះត្រូវដោះស្រាយជាបន្ទាន់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ ឬតាមមធ្យោបាយផ្សេងទៀតដែលគូភាគីព្រមព្រៀង។

## ប្រការ៦
## ការចូលជាធរមាន និងសុពលភាព

អនុស្សរណៈនេះ ចូលជាធរមានចាប់ពីពេលចុះហត្ថលេខាដោយគូភាគី។

អនុស្សរណៈនេះ មានសុពលភាពរយៈពេល ០៣(បី)ឆ្នាំ ហើយនឹងអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីគូភាគី។

## ប្រការ៧
## ការបញ្ចប់

អនុស្សរណៈនេះ អាចបញ្ចប់បានដោយភាគីណាមួយក៏បានដោយការជូនដំណឹងអំពីបំណង បញ្ចប់ការអនុវត្តអនុស្សរណៈនេះ ជូនភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ អនុស្សរណៈនេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈនេះ ត្រូវធ្វើឡើងចំនួន ០២(ពីរ)ច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងនេះមានតម្លៃស្មើគ្នា ដែលពុំមែនជាកិច្ចព្រមព្រៀងបង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។ ក្នុងករណីមានការបកស្រាយខុសគ្នា វិវាទ ឬចំណុចមិនស្របគ្នា គូភាគីត្រូវយកអត្ថបទដែលជាភាសាខ្មែរជាគោល។

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២៦

| | |
|---|---|
| **ក្រសួងមហាផ្ទៃ** | **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** |
| រដ្ឋលេខាធិការ | នាយកប្រចាំប្រទេស |
| **ជូ ប៊ុនអេង** | **ជុំ សាឯម** |

# ឧបសម្ព័ន្ធ
# សេចក្តីបរិយាយអំពីគម្រោង

| | | |
|---|---|---|
| ឈ្មោះស្ថាប័ន | ៖ | អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។ |
| ប្រភេទស្ថាប័ន | ៖ | អង្គការមិនមែនរដ្ឋាភិបាលបរទេស។ |
| អនុស្សរណៈ | ៖ | អនុស្សរណៈនៃការយោគយល់ រវាងអង្គការ(IJM) និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤។ |
| | ៖ | កិច្ចព្រមព្រៀងគម្រោងរវាងអង្គការ(IJM) ជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣។ |
| អាសយដ្ឋាន | ៖ | ផ្ទះលេខ៣៧ ផ្លូវលេខ៥៩៨ ភូមិ៣ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ |
| លេខទូរសព្ទទំនាក់ទំនង | ៖ | ០២៣ ៩៩១ ៤២០ |
| អ៊ីម៉ែល | ៖ | cambodia@ijm.org |
| ឈ្មោះគម្រោងសកម្មភាព | ៖ | កិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។ |
| ទីតាំងគម្រោង | ៖ | បណ្តារាជធានី/ខេត្ត។ |
| ដៃគូអនុវត្តគម្រោង | ៖ | សហការជាមួយនឹងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងនិងមន្ទីរសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងអង្គការដៃគូដែលមានសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| ថវិកាអនុវត្តន៍គម្រោង | ៖ | ១៩៥.០០០$(មួយរយកៅសិបប្រាំពាន់ដុល្លារអាមេរិក) រយៈពេល ០៣ឆ្នាំ។ |
| អ្នកផ្តល់ថវិកាគាំទ្រគម្រោង | ៖ | ការិយាល័យកណ្តាលរបស់ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ប្រចាំសហរដ្ឋអាមេរិក។ |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ឆ្នាំ២០២៦ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ឆ្នាំ២០២៩ |
| ចំនួនបុគ្គលិកខ្មែរ | ៖ | បច្ចុប្បន្នមានចំនួន១៣នាក់ (ស្រី៦នាក់) |
| ចំនួនបុគ្គលិកបរទេស | ៖ | ១ នាក់ (ប្រុស) |